# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីកម្រឹតជាតិនិយមរបស់អ្នកដឹកនាំខ្មែរ

web site: hoksavann.org

ថ្ងៃទី២៩ ឧសភា ២០០៥

ទីដៅត្រឹមត្រូវនិងផ្លូវប្រតិបត្តិត្រឹមត្រូវ ចាត់ទុកជាធាតុមានប្រយោជន៍សំរាប់សង្គមមនុស្សផ្លូវលោក ក៏ដូចជាផ្លូវធម៌ ។ ផ្លូវធម៌នៃព្រះពុទ្ធសាសនា ព្រះពុទ្ធជាម្ចាស់បានរកឃើញព្រះនិព្វានជាតិរំលត់ទុក្ខ ហើយផ្លូវប្រតិបត្តិទៅកាន់ទីរំលត់ទុក្ខ គឺមគ្គប្រកបដោយអង្គ៨ ។ ចំពោះផ្លូវលោក ទីដៅត្រឹមត្រូវប៉ុន្តែមាគ៌ាអនុវត្តពុំត្រឹមត្រូវនឹងធ្វើឲ្យសង្គមវិនាស ។ មួយទៀតទីដៅមិនត្រឹមត្រូវផង ការអនុវត្តន៍មិនត្រឹមត្រូវផង នោះនឹងធ្វើឲ្យសង្គមវិនាសកាន់តែឆាប់ទៅទៀត ។ ក្នុងន័យនេះ សូមលើកយកព្រឹត្តិការណ៍បីអំពីកម្រឹតជាតិនិយមរបស់អ្នកដឹកនាំខ្មែរមកធ្វើវិភាគដូចតទៅនេះ ៖

១- មេដឹកនាំខ្មែរក្រហមមានជ័យជំនះ ដឹកនាំប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៥ ដោយសារសម្តេចនរោត្តម-សីហនុ គេពុំដឹងច្បាស់ថា តើខ្មែរក្រហមមានគំនិតជាតិនិយមកម្រឹតណាទេ ហើយសកម្មភាពរបស់ខ្មែរក្រហមដែលគេដឹងច្បាស់នោះ គឺការអនុវត្តន៍លទ្ធិកុម្មុយនិស្តយ៉ាងតឹងរ៉ឹងបំផុត គឺតឹងជាងចិនកុម្មុយនិស្ត ដែលជាចៅហ្វាយខ្មែរក្រហមទៅទៀត ព្រោះចិនកុម្មុយនិស្តបដិវត្តប្រទេសខ្លួនឲ្យទៅជាកុម្មុយនិស្តនៅឆ្នាំ១៩៤៩ មិនទាន់ធ្វើបដិវត្តន៍វប្បធម៌នៅពេលនោះទេ គឺអនុវត្តជាង១០ឆ្នាំក្រោយមកទៀត ។ ប៉ុន្តែខ្មែរក្រហមបានធ្វើបដិវត្តន៍វប្បធម៌នៅពេលជាមួយគ្នានឹងការបានអំណាចនៅថ្ងៃ១៧មេសាឆ្នាំ១៩៧៥តែម្តង ដោយដេញព្រះសង្ឃដេញប្រជាជនចេញពីវត្តពីផ្ទះ ផ្សឹកព្រះសង្ឃ បិទសាលារៀនជាដើម ។ បន្ទាប់មកខ្មែរក្រហមបានអនុវត្តការកាប់សម្លាប់ប្រជាជនទូទៅ ។ បើទោះបីខ្មែរក្រហមបានពោលអះអាងថា ខ្លួនអនុវត្តបែបនេះដើម្បីធ្វើឲ្យប្រទេសកម្ពុជាបានសំបូរសប្បាយចំរើនរុងរឿងក៏ដោយ ប៉ុន្តែសកម្មភាពរបស់ខ្លួនបានអនុវត្តខុសមាគ៌ា ខុសដោយកាប់សម្លាប់ប្រជាពលរដ្ឋរបស់ខ្លួន ពុំមែនជាឧត្តមគតិជាតិនិយមទេ គឺជាអំពើបំផ្លាញជាតិ ជាជនប្រល័យពូជសាសន៍ ដែលនឹងត្រូវកាត់ទោសក្នុងតុលាការឯករាជ្យមួយក្នុងពេលខាងមុខនេះ ។

២- ព្រឹត្តិការណ៍ឆ្នាំ១៩៧០ មានបាតុកម្មប្រជាពលរដ្ឋមួយនៅខេត្តស្វាយរៀង ប្រឆាំងនឹងកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលបោះទីតាំងនៅលើដីខ្មែរ ។ បន្ទាប់មកមានបាតុកម្មមួយទៀតធ្វើនៅភ្នំពេញ មានគោលបំណងដូចគ្នា ប្រើអំពើហឹង្សាវាយស្ថានទូតយួនខាងជើងនិងយៀកកុង ។ សម្តេចនរោត្តម-សីហនុ ដែលពេលនោះព្រះអង្គកំពុងព្យាបាលព្រះរោគនៅទីក្រុងប៉ារីសប្រទេសបារាំង បន្ទាប់ពីបានឮដំណឹងនេះហើយ ក៏មានការក្រេវក្រោធយ៉ាងខ្លាំង ដោយចោទរដ្ឋាភិបាលស្រោចស្រង់ជាតិរបស់លន់-នល់ ថាជាជនក្បត់ចូលដៃអាមេរិក ។ ដោយចង់បញ្ជាក់ការពិត លោកលន់-នល់បានចាត់លោកយ៉ែម-សំបូរ តំណាងរាជរដ្ឋាភិបាល និងទ្រង់នរោត្តម-កន្តុល តំណាងរាជវង្សានុវង្ស ទៅថ្វាយដំណឹងសម្តេចនៅទីក្រុងប៉ារីស អំពីគ្រោះថ្នាក់នៃប្រទេសកម្ពុជាតាមឯកសារបន្ថែមទៀត ដែលយកបានពីក្នុងស្ថានទូតយួននៅភ្នំពេញ ដើម្បីថ្វាយដំណឹងដល់សម្តេច ។ ជាអកុសល សម្តេចនរោត្តម-សីហនុពុំអនុញ្ញាតឲ្យគណៈប្រតិភូទាំងពីររូបនេះជួបឡើយ ថែមទាំងចោទថា ក្រុមលោកលន់-នល់ជាជនក្បត់ បើព្រះអង្គយាងត្រឡប់ទៅភ្នំពេញវិញ នឹងកំទេចចោល ។ តាមដំណឹងមួយថា រដ្ឋាភិបាលលោកលន់-នល់មានការភិតភ័យណាស់ បន្ទាប់ពីឮដំណឹងអវិជ្ជមាននេះ ដោយសម្តេចមិនឲ្យជួប និងដាក់ឲ្យរដ្ឋាភិបាលមានទោសទៀត ។ ដោយទឹកលិចជិតដល់ច្រមុះ ដោយសារយៀកកុង-យៀកណាមខាងជើងនៅពាសពេញប្រទេសកម្ពុជា ជាចារកិច្ចបង្កប់ខ្លួនផង ហើយខ្លាចសម្តេចវិលមកវិញធ្វើទោសខ្លួនផង ក៏កើតព្រឹត្តិការណ៍១៨មិនា១៩៧០ គឺទម្លាក់សម្តេចពីតំណែងព្រះប្រមុខរដ្ឋទៅ ដោយគំនិតថា សម្តេចមិនគាំទ្រប្រជាពលរដ្ឋ បែរទៅជាកាន់ជើងយៀកកុង-យៀកណាមខាងជើងទៅវិញ ។ ពេលដែលគេទម្លាក់ សម្តេចកំពុងស្ថិតនៅទីក្រុងមូស្គូនៃសហភាពសូវៀត ។ បន្ទាប់មកព្រះអង្គបន្តដំណើរទៅប្រទេសចិនកុម្មុយនិស្ត ។ ពេលនោះចិនកុម្មុយនិស្តបានទទួលសម្តេចជាព្រះប្រមុខរដ្ឋ ។ ពេលជាមួយគ្នានោះ ស្ថានទូតចិនកុម្មុយនិស្តនៅភ្នំពេញ បានលួចទៅចរចាជាមួយលន់-នល់ដោយសម្ងាត់ថា បើលោកលន់-នល់សុខចិត្តឲ្យកងទ័ពយៀកកុង-យៀកណាមខាងជើងប្រើប្រាស់ទឹកដីខ្មែរជាបន្តទៅទៀតនៅប៉ែកខាងកើត ដើម្បីវាយរដ្ឋការយួនខាងត្បូងនិងអាមេរិកដូចសម័យសម្តេចសីហនុនោះ ការទម្លាក់សម្តេចនរោត្តម-សីហនុជាកិច្ចការផ្ទៃក្នុងរបស់ខ្មែរ ចិនមិនលូកដៃចូលជ្រៀតជ្រែកឡើយ ។ ការចរចាអស់រយៈវេលាចំនួន១អាទិត្យ លោកលន់-នល់ពុំព្រមតាមចិនឡើយ ព្រោះការទម្លាក់សម្តេចសីហនុពីព្រះប្រមុខរដ្ឋនោះ គឺដើម្បីវាយយៀកកុងនិងយួនខាងជើងឲ្យចេញពីទឹកដីប្រទេសកម្ពុជា ។ ចិនអស់ផ្លូវ ក៏ហៅបុគ្គលិកទូតចិននៅភ្នំពេញឲ្យត្រឡប់ទៅប្រទេសខ្លួនវិញ ហើយក៏ចាប់ផ្តើមគាំទ្រសម្តេចសីហនុ ដែលមានសកម្មភាពជាបន្តបន្ទាប់គ្នា មានឧបត្ថម្ភឲ្យសម្តេចសីហនុប្រជុំជាមួយនាយករដ្ឋមន្ត្រីយួននិងលាវនៅកង់តុងប្រទេសចិន ដើម្បីបង្កើតរណសិរ្សជាតិរួបរួមនៃប្រទេសឥណ្ឌូចិន ដើម្បីវាយអាមេរិកនិងរដ្ឋការយួនខាងត្បូង និងរដ្ឋការលន់-នល់ ។ ក្រៅពីនោះ ចិនគាំទ្រឲ្យសម្តេចបង្កើតរណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដើម្បីវាយរដ្ឋការលន់-នល់ដែលអាមេរិកគាំទ្រ ។

ការទាញយកប្រវត្តិក្នុងវគ្គមួយដ៏សង្ខេបនេះ ចង់ឆ្លុះបញ្ចាំងមើលគំនិតជាតិនិយមរបស់អ្នកដឹកនាំខ្មែរ មានកម្រឹតបែបណា ព្រោះទំនាស់ផ្ទៃក្នុងនេះ បានធ្វើឲ្យប្រជាពលរដ្ឋខ្មែររងទុក្ខវេទនា ស្លាប់ព្រាត់ប្រាស់គ្នាក្នុងសង្គ្រាមប្រាំឆ្នាំ ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥។ បន្ទាប់ពីជ័យជំនះខ្មែរក្រហមបានកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរអស់រាប់លាននាក់ ។ តពីនោះមកទៀតយួនបានចូលមកឈ្លានពានប្រទេសកម្ពុជា ហើយបន្តសង្គ្រាមអស់១២ឆ្នាំទៀត ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩១ ។ ទោះបីប្រទេសកម្ពុជាមានសន្តិភាព ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិក៏ដោយ ក៏គណបក្សនយោបាយខ្មែរបច្ចុប្បន្ននេះ នៅតែមានការរកាំរកូសគ្នានៅឡើយ ។ បើខ្មែរនិងខ្មែរមានគំនិតជាតិនិយមឲ្យខ្ពស់ ដឹកលល់ផលប្រយោជន៍ជាតិឲ្យខ្ពស់ជាងប្រយោជន៍ផ្ទាល់ខ្លួននិងបក្សពួកខ្លួននោះ ព្រឹត្តិការណ៍ដូចពោលមកហើយនោះ នឹងពុំកើតមានឡើយ ។ យ៉ាងណាមិញ ពេលដែលទ្រង់កន្តុលនិងលោកយ៉ែម-សំបូរជាគណៈប្រតិភូ ដែលលោកលន់-នល់ចាត់ទៅ បើសម្តេចនរោត្តម-សីហនុប្រើវិចារណញ្ញាណឲ្យខ្ពស់ សព្វព្រះទ័យឲ្យកូនចៅទាំងពីរនេះជួបពិភាក្សាគ្នាជាគ្រួសារ អំពីគ្រោះថ្នាក់របស់ជាតិ ឲ្យមានឯកភាពជាតិ កុំជឿបរទេសញុះញង់នោះ សង្គ្រាម៥ឆ្នាំ វាល

ពិឃាត យួនចូលឈ្លានពាននឹងពុំកើតមានឡើយ ។ ព្រះពុទ្ធសាសនានិយាយថា ធម៌អស្មិមានៈនេះ បើស្ថិតនៅលើបុគ្គលណា វាធ្វើឲ្យអន្តរាយដល់ខ្លួនផង ដល់សង្គមផង ។ ការមិនព្រមជួបនិយាយគ្នា ដើម្បីបង្កើតការទុកចិត្តគ្នាតែមួយប៉ប្រិចភ្នែក ធ្វើឲ្យប្រជាពលរដ្ឋខ្មែររងទុក្ខវេទនាអស់ ១០-២០ឆ្នាំ ។ ពិសេសអ្នកដឹកនាំគេ ដែលគេជឿទុកចិត្ត បើដើរផ្លូវត្រូវ នឹងធ្វើឲ្យប្រទេសបានសុខចំរើន ប៉ុន្តែបើដើរផ្លូវខុសវិញ នឹងធ្វើឲ្យជាតិវិនាសអន្តរាយ ។ អ្នកដឹកនាំគេត្រូវតែមានធម៌ក្នុងខ្លួន ។ ធម៌ក្នុងទីនេះសំដៅយកការដឹកនាំឲ្យបានល្អ ព្រោះអ្នកដឹកនាំគេ ប្រៀបដូចអ្នកកាច់ចង្កូតកប៉ាល់ឬនាវាឬក៏រថយន្ត ។ បើកាច់ចង្កូតខុសផ្លូវ នឹងធ្វើឲ្យគ្រោះថ្នាក់ដល់អ្នកជិះ ។

៣- តាមពត៌មានថា លោកសម-រង្ស៊ីស្នើសុំជួបទ្រង់រណឫទ្ធិ ដើម្បីដោះស្រាយអំពីការប្តឹងផ្តល់គ្នា និងអំពីការដកអភ័យឯកសិទ្ធិ ។ ទ្រង់រណឫទ្ធិសំដែងការមិនចង់ជួបដោយពោលថា មុននឹងជួបទ្រង់ត្រូវជួបតុលាការសិន ។ បើពិនិត្យតាមដានមើលព្រឹត្តិការណ៍ខ្មែរ ជាពិសេសបញ្ហាធំៗរបស់ជាតិ ដែលមានវិបត្តិជាបន្តបន្ទាប់កន្លងមក ពុំដែលដោះស្រាយបានតាមរយៈតុលាការឡើយ ច្រើនតែដោះស្រាយបានតាមរយៈការចរចាសំរបសំរួលគ្នា ។ រដ្ឋកម្ពុជាដែលដឹកនាំដោយបក្សប្រជាជន ក៏តុលារធ្លាប់កាត់ទោសមេខ្មែរក្រហម, បក្សប្រជាជនក្នុងរដ្ឋាភិបាលចំរុះ ក៏បានកាត់ទោសទ្រង់រណឫទ្ធិនៅឆ្នាំ១៩៩៧ជាដើមតែការកាត់ទោសនោះគ្មានបានការអ្វីឡើយ ទីបំផុតឃើញតែសំរុះសំរួលជានានឹងគ្នាវិញ ។ ដំណោះស្រាយតាមផ្លូវច្បាប់ជាការប្រសើរហើយ ដើម្បីចៀសវាងយុទ្ធវិធីដោយការធ្វើចំបាំង បើតុលាការនោះមានយុត្តិធម៌ ប៉ុន្តែគេដឹងឮគ្រប់ៗគ្នាហើយថាតុលាការខ្មែរអសមត្ថភាព ពុំឯករាជ្យ លំអៀងទៅរកអ្នកកាន់អំណាច ។ ដូច្នេះមានតែវិធីនិយាយសម្របសម្រួលគ្នាដោយសន្តិវិធី ដើម្បីទម្លុះឧបសគ្គក្នុងការអភិវឌ្ឍន៍ប្រទេស ។ បក្សប្រជាជននិងបក្សហ៊្វុនស៊ិនប៉ិចបានសំរបសំរួលធ្វើការជាមួយគ្នា បានជាលែងធ្វើការរិះគន់គ្នាប្តឹងផ្តល់គ្នា ។ចំណែកបក្សសម-រង្ស៊ីជាមួយបក្សទាំងពីរនេះ ការប្តឹងផ្តល់គ្នា ដោយសារមិនបានសំរបសំរួលធ្វើការជាមួយគ្នា ។ លោកសម-រង្ស៊ីមានចំណោះជិះកឯង ដោយជឿទ្រង់រណឫទ្ធិផ្កាប់មុខ ខ្លួនមានតំណាងរាស្ត្រ២៤នៅតែពីរទៀតស្មើនឹងតំណាងរាស្ត្ររបស់ហ៊្វុនស៊ិនប៉ិច នៅពេលដែលសម្តេចនរោត្តម-សីហនុអតីតព្រះមហាក្សត្រខ្មែរ ព្រះអង្គធ្វើរដ្ឋាភិបាលចំរុះត្រីភាគី ស្រាប់តែពុំដឹងជារឿងបែបម៉េច លោកសម-រង្ស៊ីពុំធ្វើតាមព្រះមហាក្សត្រ ដែលជាទៅតោងកន្ទុយក្បិនទ្រង់រណឫទ្ធិ ឲ្យទ្រង់រណឫទ្ធិពិភាក្សាក្នុងការបង្កើតរដ្ឋាភិបាលជាមួយបក្សប្រជាជនក្នុងនាមខ្លួនទៅវិញ ។ តាមពិត លោកសម-រង្ស៊ីត្រូវតែពិភាក្សាត្រីភាគីស្មើមុខគ្នា បែងចែកតំណែងក្នុងរដ្ឋាភិបាលចំរុះនេះ មិនត្រូវចែកបន្តពីទ្រង់រណឫទ្ធិនៃបក្សហ៊្វុនស៊ិនប៉ិចឡើយ ។ លុះទ្រង់រណឫទ្ធិបានចែកតំណែងត្រូវរ៉ូវគ្នាជាមួយបក្សប្រជាជនហើយ យកមកចែកបក្សសម-រង្ស៊ីក៏បែកគ្នាត្រឹមនេះឯង ដោយបក្សសម-រង្ស៊ីទាមទារតំណែងខ្លះទៀត ឲ្យលើសពីតំណែងដែលបក្សហ៊្វុនស៊ិនប៉ិចប្រុគល់ឲ្យ តែបក្សហ៊្វុនស៊ិនប៉ិចមិនព្រមចែកឲ្យ ។ បក្សសម-រង្ស៊ីក៏ឈប់ធ្វើរដ្ឋាភិបាលចំរុះជាមួយបក្សទាំងពីរនោះទៅ ដែលកើតជាផលវិបាក គឺមានសមាជិកខ្លះនៃបក្សសម-រង្ស៊ី ទៅរត់ចូលបក្សដទៃទៀត ដើម្បីបានបៀវត្សចិញ្ចឹមជីវិត ។ ចំណែកបក្សប្រជាជននិងបក្សហ៊្វុនស៊ិនប៉ិចបានត្រូវរ៉ូវគ្នាល្អណាស់ ហើយឆ្លាតបំផុតគឺបក្សប្រជាជន កាលពីឆ្នាំ ១៩៩៣ បក្សប្រជាជនបានប្រធានរដ្ឋសភា ហើយបក្សហ៊្វុនស៊ិនប៉ិចបាននាយករដ្ឋមន្ត្រីទី១ ហើយដើម្បីបានក្តោបអំណាចក្នុងនីតិប្រតិបត្តិផង គណប្រជាជនសុំតំណែងនាយករដ្ឋមន្ត្រីទី២ ដែលប្លែកពីគេក្នុងពិភពលោក ។ ដូច្នេះបក្សប្រជាជនបានក្តោបអំណាចក្នុងនីតិបញ្ញត្តិគឺសភាផង និងនីតិប្រតិបត្តិ គឺរដ្ឋាភិបាលផង ។ បានសេចក្តីថា មុននឹងនាយករដ្ឋមន្ត្រីទី១សំរេចអ្វីបាន លុះត្រាតែយល់ព្រមពីនាយករដ្ឋមន្ត្រីទី២ផង ។ ឥឡូវនេះ អាណត្តិទី៣មានលក្ខណៈដូចគ្នា គឺទ្រង់រណឫទ្ធិជាប្រធានរដ្ឋសភាខាងនីតិបញ្ញត្តិ ប៉ុន្តែគេតែងតាំងតំណែងមួយទៀត គឺទ្រង់រណឫទ្ធិជាទីប្រឹក្សាពិសេសរបស់រាជរដ្ឋាភិបាល គឺគេទាញនីតិបញ្ញត្តិនិងនីតិប្រតិបត្តិរលាយចូលគ្នា ។ បានសេចក្តីថា បើរដ្ឋាភិបាលចង់កែប្រែច្បាប់ ឬចង់ឲ្យសភាធ្វើច្បាប់បែបណា គ្រាន់តែនិយាយជាមួយទ្រង់រណឫទ្ធិទុកជាបានការព្រោះសមាជិកសភា តែងតែស្តាប់ប្រធានបក្ស បើមិនស្តាប់ទេខ្លាចត្រូវប្រធានដកពីតំណែង ព្រោះបោះឆ្នោតជាសមាមាត្រ ពុំមែនជាឯកត្តនាម គឺតំណាងរាស្ត្រស្រេចលើលើប្រធានបក្សចាត់តាំង ។ ដូច្នេះ លក្ខណៈនេះមានគ្រោះថ្នាក់ណាស់ ព្រោះប្រទេសប្រជាធិបតេយ្យ គេឲ្យអំណាចទាំងពីរនេះដាច់ចេញពីគ្នា ។ ឥឡូវនេះទ្រង់រណឫទ្ធិកំពុងសប្បាយភ្លេចខ្លួនដោយតំណែងពិសេសទាំងពីរនេះ ហើយតែងតែពោលថា កិច្ចការអ្វីចាំពិគ្រោះជាមួយសម្តេចនាយកសិន ។ ដូច្នេះ លោកសម-រង្ស៊ីមិនចាំបាច់សុំជួបពិភាក្សាជាមួយទ្រង់រណឫទ្ធិទេ គួរសុំជួបសម្តេចនាយកវិញព្រោះបើជួបទ្រង់រណឫទ្ធិ នៅតែពុំបានសំរេចដដែល ។

តើគំនិតជាតិនិយមរបស់អ្នកដឹកនាំខ្មែរមានកម្រឹតត្រឹមណា ឬត្រឹមតែអំណាចប៉ុណ្ណោះទេ ? ។ បើតុលាការខ្មែរពេលនេះពុំអាចរកយុត្តិធម៌ជូនភាគីខ្មែរនិមួយៗបានទេ គួរសំរបសំរួលគ្នាទៅ ហើយមធ្យោបាយនេះធ្លាប់បានធ្វើមកហើយ ដូចព្រឹត្តិការណ៍ឆ្នាំ១៩៩៧ជាដើម ដែលគេកាត់ទោសទ្រង់រណឫទ្ធិ ទីបំផុតសំរួលគ្នាវិញ កុំឲ្យដូចព្រឹត្តិការណ៍ថ្ងៃ១៨មីនា១៩៧០វិលមកវិញ ដោយពេលនោះ សម្តេចនរោត្តម-សីហនុនិងលោកលន់-នល់ពុំបានពិភាក្សាគ្នា ក៏បង្កើតសង្គ្រាមច្បាំងគ្នា និងធ្វើឲ្យប្រជាពលរដ្ឋរងទុក្ខវេទនា២០-៣០ឆ្នាំ ។ ការវិភាគនេះដោយចិត្តបរិសុទ្ធ គ្មានបំណងបំផ្លាញគណបក្សណាឬវរជនណាឡើយ មានបំណងតែម៉្យាង គឺចង់ឲ្យប្រទេសកម្ពុជារស់រានមានជីវិត ប្រកបដោយសុខសន្តិភាពនិងចំរើនលូតលាស់ ដូចប្រទេសដែលលូតលាស់ក្នុងលោក ។៚